# ទំនុកអរព្រះគុណព្រះអម្ចាស់

អ្នកទំនុកដំកើង តែងសំដែងអារម្មណ៍របស់ពួកគេ នៅពេលពួកគេកើតទុក្ខ ឬសប្បាយ ផ្ទុយពីទំនុកដំកើងនៃការយំសោក នោះមានទំនុកដំកើងនៃការអរព្រះគុណ។ យើងបានសង្កេតរួចមកហើយថា អ្នកទំនុកដំកើងបានពេញដោយការទុក្ខសោក និងការលំបាក ពួកគេនៅតែទុកចិត្តលើព្រះអម្ចាស់ និងសេចក្ដីមេត្តាករុណាទ្រង់។ តែទំនុកអរព្រះគុណ មានចេញនូវអំណរបន្ទាប់ពីព្រះបានរំដោះពីការទុកសោក និងការលំបាក។

## ទម្រង់ និងផ្ទៃរឿង របស់ទំនុកអរព្រះគុណ

វាមានការលំបាកក្នុងការជ្រើសរើសទំនុកអរព្រះគុណ តែយើងអាចមានចំណុចសំខាន់ពីរ ដែលចាត់ទុកថាជាទំនុកអរព្រះគុណ៖ (១) អ្នកទំនុកដំកើងរៀបរាប់ពីវិបត្តរបស់គាត់ (២) ការអះអាងពីការរួចផុតពីវិបត្តនិងការរំដោះឲ្យផុត។ វាផ្ទុយពីទំនុកដំកើងយំសោក វិបត្តនៅតែបន្តមាននាពេលស្មូតទំនុកយំសោក រីឯទំនុកអរព្រះគុណវិញ វិបត្តបានផុតទៅជាពេលស្មូតទំនុកអរព្រះគុណ។ ដូច្នេះ យើងអាចបែងចែកទំនុកអរព្រះគុណជាបួនផ្នែកធំៗ៖

### ១. សេចក្ដីផ្ដើម

ការនេះប្រហែលជាមានទម្រង់មានបំណងថ្វាយបង្គំ និងពីហេតុផលថា ហេតុអ្វី? ឧទាហរណ៍ដ៏ល្អគឺចាប់ផ្ដើមដោយសេចក្ដីថ្លែងការណ៍ ក្នុងទំនុកដំកើង ៣០:១ "ឱព្រះយេហូវ៉ាអើយ ទូលបង្គំសរសើរទ្រង់ដ្បិតទ្រង់បានលើកទូលបង្គំឡើងវិញ មិនបានបើកឲ្យពួកខ្មាំងសត្រូវមានសេចក្តីអំណរ ដោយឈ្នះទូលបង្គំឡើយ"។ ស្ដេចដាវីឌបង្ហាញពីបំណងសរសើរដល់ព្រះអម្ចាស់ ដោយដឹងគុណចំពោះការដែលព្រះអម្ចាស់មិនបានបើកឲ្យខ្មាំងសត្រូវ...ឈ្នះដាវីឌ។

សេចក្ដីផ្ដើមក៏អាចមានទម្រង់ផ្សេងផងដែរ។ ឧទាហរណ៍ ទំនុកដំកើង ៩២:១-៤ គឺជាសេចក្ដីថ្លែងការណ៍ពីភាពសមរម្យនៃការថ្វាយបង្គំព្រះ៖

នេះជាការល្អហើយ គឺដែលនឹងអរព្រះគុណដល់ព្រះយេហូវ៉ា
ហើយច្រៀងសរសើរដល់ព្រះនាមនៃទ្រង់ ជាព្រះដ៏ខ្ពស់បំផុត
ព្រមទាំងសំដែងពីសេចក្តីសប្បុរសនៃទ្រង់នៅពេលព្រឹក
ហើយពីសេចក្តីស្មោះត្រង់របស់ទ្រង់រាល់តែយប់
ដោយប្រដាប់ភ្លេងមានខ្សែ១០ និងពិណ
ហើយដោយសូរចាប់ស៊ុងយ៉ាងរងំ
ដ្បិត ឱព្រះយេហូវ៉ាអើយ
ទ្រង់បានឲ្យទូលបង្គំមានសេចក្តីអំណរ

ដោយកិច្ចការរបស់ទ្រង់ ទូលបង្គំនឹងបន្លឺឡើង
ដោយអំណរ ចំពោះការនៃព្រះហស្តទ្រង់

នៅក្នុងសេចក្តីថ្លែងការណ៍ អ្នកទំនុកដំកើងបានផ្តល់នូវហេតុផល ហេតុអ្វីបានជាគាត់ជឿថា ការថ្វាយបង្គំត្រូវតែជាការសមរម្យត្រូវធ្វើ (ជាការល្អ) ដោយព្រោះគាត់មានមានការអស្ចារ្យពីទង្វើរបស់ព្រះអម្ចាស់នៅក្នុងប្រវត្តិសាស្ត្រ។ ក្នុងលក្ខណៈបែបនេះ សេចក្តីផ្តើមអាចជាការប្រកាសហៅដោយបញ្ជាឲ្យអរគុណ ឬសរសើរ ដូចជាមាននៅក្នុងទំនុកដំកើង ១១៨:១ "ចូរអរព្រះគុណដល់ព្រះយេហូវ៉ា ដ្បិតទ្រង់ល្អ សេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប"។ នៅក្នុង៦២ បានបង្ហាញយ៉ាងច្បាស់ អ្នកថ្វាយបង្គំព្រះបានតប ដោយបញ្ជាក់ពីសេចក្តីសប្បុរសដ៏ស្ថិតស្ថេររបស់ព្រះអម្ចាស់ ដោយៈ ឥឡូវនេះ គួរឲ្យសាសន៍អ៊ីស្រាអែលពោលថា សេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប"

ដូច្នេះ សេចក្តីផ្តើម មិនមានទម្រង់ជាក់លាក់ដូចគ្នារហូតនោះទេ ទុកណាជាទំនុកដំកើងខ្លះបានបង្ហាញពីអ្នកទំនុកដំកើងមានបំណងអរគុណព្រះអម្ចាស់ ឬចូលទៅថ្វាយបង្គំព្រះ។

## ២. សេចក្តីរាយការណ៍ពីវិបត្ត

ដូចជាបាននិយាយរួចមកហើយថា ការនិយាយពីវិបត្តគឺជាការសំខាន់មួយក្នុងចំណោមការសំខាន់ទាំងពីរនៅក្នុងទំនុកអរព្រះគុណ។ ការនិយាយពីវិបត្តនេះអាចខ្លី នៅក្នុងទំនុកដំកើងខ្លះ (៣២:៣-៤; ៤០:២-៣; ៩២:១០-១១; ១២០:១, ៦) ឬជារឿងវែងបន្តិច ដូចមាននៅក្នុង ១៨:៤-៥, ៧-១៩; ៣០:២-៣, ៦-៩, ១១-១២ក; ៣១:៩-១៣, ២១-២២; ៦៦:៥-១២)។

## ៣. ការរំដោះជាព្រឹត្តិការណ៍បានកើតឡើងរួចមកហើយ

នេះគឺជាការសំខាន់ទីពីរនៅក្នុងទំនុកអរព្រះគុណ។ ដូចជាយើងដឹងរួចមកហើយថា ការរំដោះនេះមិនបាននិយាយអះអាងនៅក្នុងទំនុកយំសោកទេ។ ការរំដោះដោយព្រះចេស្តារបស់ព្រះយេហូវ៉ា នោះបានបំប្រែស្ថានភាពនៃវិបត្តរបស់អ្នកទំនុកដំកើង បានសរសើរដំកើងព្រះអម្ចាស់វិញ។

## ៤. សេចក្តីបញ្ចប់

ផ្នែកនេះមានការច្របូកច្របល់ដូចនៅក្នុងសេចក្តីផ្តើមផងដែរ។ វាប្រហែលជាមានទម្រង់ជាការសន្យា ឬប្តេជ្ញាចិត្តសរសើរព្រះអម្ចាស់ ឬធ្វើការថ្វាយយញ្ញបូជា ដូចនៅក្នុង ទំនុកដំកើង ១១៦:១៧-១៩៖

"ទូលបង្គំនឹងថ្វាយដង្វាយជាសេចក្តីអរព្រះគុណដល់ព្រះយេហូវ៉ា
ហើយនឹងអំពាវនាវដល់ព្រះនាមទ្រង់ ខ្ញុំនឹងលាបបំណន់របស់ខ្ញុំចំពោះព្រះយេហូវ៉ា
អើនៅមុខបណ្ដាជនទាំងប៉ុន្មានរបស់ទ្រង់ផង

គឺនៅក្នុងព្រះលាននៃដំណាក់ព្រះយេហូវ៉ា
គឺនៅកណ្តាលឯង
ឱក្រុងយេរូសាឡិមអើយ ចូរសរសើរដល់ព្រះយេហូវ៉ាចុះ៉

សេចក្តីបញ្ចាប់ក៏មាននិយាយពី បំណងរបស់អ្នកថ្វាយបង្គំសរសើរដល់ព្រះអម្ចាស់ និងមើលទៅវាដូចនឹងសេចក្តីផ្តើមផងដែរ ដូចនៅក្នុងទំនុកដំកើង ១១៨:២៨-២៩ ដែលបញ្ចប់ដោយបញ្ញានូវការសរសើរដំកើងព្រះ៖

៉ទ្រង់ជាព្រះនៃទូលបង្គំ
ហើយទូលបង្គំនឹងអរព្រះគុណដល់ទ្រង់។
ចូរសរសើរដល់ព្រះយេហូវ៉ាចុះ
ដ្បិតទ្រង់ល្អ
សេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប។៉

ដូចគ្នានឹង ទំនុកដំកើង ៣២:១១ បញ្ចប់ដោយការប្រកាសហៅឲ្យសរសើរដំកើង៖ ៉ឱមនុស្សសុចរិតរាល់គ្នាអើយ ចូរមានចិត្តសប្បាយ ហើយរីករាយឡើង ក្នុងព្រះយេហូវ៉ាចុះ អស់អ្នកដែលមានចិត្តទៀងត្រង់អើយ ចូរនាំគ្នាស្រែកឡើងដោយអំណរចុះ។៉

សេចក្តីថ្លែងការណ៍នៃដំណោះស្រាយរបស់អ្នកទំនុកដំកើងដើម្បីសរសើរព្រះតបចំពោះអ្វីដែលព្រះអម្ចាស់បានធ្វើសំរាប់គាត់ មាននៅក្នុងទំនុកដំកើង ៣០:១១-១២៖

៉នោះទ្រង់បានផ្លាស់ការយំសោករបស់ទូលបង្គំ
ឲ្យទៅជាសេចក្តីត្រេកអរទៅវិញ
ទ្រង់បានផ្លាស់សំពត់សំរាប់កាន់ទុក្ខចេញ ឲ្យ
ទូលបង្គមបានស្លៀកពាក់សេចក្តីអំណរឡើង
ដើម្បីឲ្យចិត្តទូលងប្តំបានច្រៀងសរសើរដល់ទ្រង់ឥតនៅស្ងៀមឡើយ
ឱព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំអើយ ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ជាដរាបទៅ។៉

សេចក្តីបញ្ចប់អាចមានទម្រង់ជាសេចក្តីថ្លែងពីភាពស្មោះត្រង់របស់ព្រះអម្ចាស់(១៨:៥០ ៉*ទ្រង់ប្រោសសេចក្តីសង្គ្រោះយ៉ាងធំ ដល់ស្តេចរបស់ទ្រង់ ក៏សំដែងសេចក្តីសប្បុរស ដល់អ្នកដែលទ្រង់បានចាក់ប្រេងតាំងឲ្យ គឺដល់ដាវីឌ និងពូជពង្សតរៀងទៅ*៉; ៩២:១៥ ៉*ដើម្បីនឹងសំដែងឲ្យឃើញថា ព្រះយេហូវ៉ាទ្រង់ទៀងត្រង់ ទ្រង់ជាថ្មដានៃខ្ញុំ គ្មានសេចក្តីទុច្ចរិតណានៅក្នុងទ្រង់ឡើយ*) និងមានខ្លះទៀត បានសារភាពចំពោះសេចក្តីត្រូវការរបស់អ្នកទំនុកដំកើង ដោយការសុំ (៤០:១៧) ៉*ឯទូលបង្គំ ៗក្រីក្រ ហើយទុគ៌ត ប៉ុន្តែព្រះអម្ចាស់ទ្រង់នឹកដល់ទូលបង្គំដែរ ទ្រង់ជាជំនួយ ហើយជាអ្នកប្រោសឲ្យទូលបង្គំរួចផង ឱព្រះនៃទូលបង្គំអើយ សូមកុំបង្អង់ឡើយ*៉។

មានពាក្យជាប្រាជ្ញា ឬដំបូន្មាននៅក្នុងទំនុកដំកើងខ្លះផងដែរ ដូចមាននៅក្នុងទំនុកដំកើង ៣២:៨-១០៖

"អញនឹងបង្ហាត់បង្រៀនឲ្យឯងស្គាល់ផ្លូវ
ដែលឯងត្រូវដើរ អញនឹងទូន្មានឯង
ដោយភ្នែកអញមើលឯងជាប់
កុំឲ្យឯងធ្វើដូចជាសេះ ឬលាកាត់ ដែលគ្មានប្រាជ្ញា
ដែលគេត្រូវដាក់បង្ហៀ ហើយនឹងបង្ហៀរ ដើម្បីទប់វា
ក្រែងវាមិនព្រមមកឯឯងនោះឡើយ
ឯមនុស្សអាក្រក់គេនឹងមានទុក្ខព្រួយជាច្រើន
តែអ្នកណាដែលទុកចិត្តនឹងព្រះយេហូវ៉ា
នោះនឹងមានសេចក្ដីសប្បុរសនៅព័ទ្ធជុំវិញខ្លួន"

ហើយពាក្យបែបនេះ មាននៅក្នុងទំនុកដំកើង ១៨:២៥-៣៦; ៩២:៦-៧, ១២-១៥។

## ប្រភេទទំនុកអរព្រះគុណ

**១. ទំនុកអរព្រះគុណបែបបុគ្គលភាព**

ទំនុកអរព្រះគុណបែបបុគ្គលភាពមានទំនុកដំកើង ១៨, ៣០, ៣១, ៣២, ៤០, ៦៦, ៩២, ១១៦, ១១៨ និង១២០។ ឧទាហរណ៍ ក្រៅពីកណ្ឌទំនុកដំកើង ទំនុកអរព្រះគុណមាននៅក្នុង អេសាយ ៣៨:១០-២០ និង យ៉ូណាស ២:៣-៩។

**២. ទំនុកអរព្រះគុណបែបសហគមន៍**

ទំនុកអរព្រះគុណបែបសហគមន៍មានទំនុកដំកើង ៦៥, ៦៦, ១០៧, ១១៨, ១២៤ និង១២៩ ។